# សំណួរ និងចម្លើយ

## សំខាន់ៗដែលលោកអ្នកគួរយល់ដឹងអំពីផលិតផល SAFElife

PRUDENTIAL
ព្រូដិនសល ធានារ៉ាប់រងអាយុជីវិត

កម្រងសំណួរចម្លើយនេះត្រូវបានរៀបរៀងឡើងក្នុងគោលបំណងផ្តល់ជូនលោកអ្នកនូវព័ត៌មានសង្ខេបមួយចំនួនទាក់ទងនឹងអត្ថប្រយោជន៍នៃសេវាធានារ៉ាប់រងអាយុជីវិត។ សូមអានឯកសារនេះ រួមជាមួយនឹងសៀវភៅ ខ និង លក្ខខណ្ឌ ដើម្បីយល់កាន់តែច្បាស់អំពីបណ្ណសន្យារ៉ាប់រងនេះ

### 1. តើអត្ថប្រយោជន៍ធានារ៉ាប់រងរបស់ផលិតផល SAFElife ជាអ្វី?

SAFElife ជាគម្រោងការការពារមូលដ្ឋានបឋមដែលនឹងជួយការពារលោកអ្នក និងក្រុមគ្រួសារលោកអ្នកពីហេតុការណ៍អកុសលកើតមាននានា ដែលនេះអាចជួយក្រុមគ្រួសារលោកអ្នកមានពេលវេលាសម្របខ្លួនទៅក្នុងស្ថានភាពលំបាកមួយនោះ តាមរយៈអត្ថប្រយោជន៍ហិរញ្ញវត្ថុដែលបានផ្តល់ជូន។ SAFElife នឹងជួយលោកអ្នក និងក្រុមគ្រួសារតាមរយៈគុណតម្លៃដូចខាងក្រោម៖

- ទឹកប្រាក់ធានារ៉ាប់រងសរុប ១០០% ដែលអាចជួយសម្រាលបន្ទុករបស់ក្រុមគ្រួសារលោកអ្នក ក្នុងករណីលោកអ្នកទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ដែលមិនបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ (ករណីគ្រោះអកុសលកើតឡើងបន្ទាប់ពី៩ខែដំបូងនៃរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រង)។
- ទឹកប្រាក់ធានារ៉ាប់រងសរុប ២០០% ដែលអាចជួយសម្រាលបន្ទុករបស់ក្រុមគ្រួសារលោកអ្នក ក្រោយពេលជួបគ្រោះអកុសលដែលបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ (ទោះបីជាកើតឡើងក្នុងរយៈពេលណាមួយក៏ដោយក្នុងរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រង)។

ផលិតផល SAFElife ជាផលិតផលធានារ៉ាប់រងអាយុជីវិតសមស្របសម្រាប់លោកអ្នក និងក្រុមគ្រួសារ ដោយលោកអ្នកគ្រាន់តែចំណាយទឹកប្រាក់ចាប់ពី ៣០,០០០ រៀល (ឬប្រហែល ៧.៥ ដុល្លារ) ប៉ុណ្ណោះក្នុងមួយខែសម្រាប់បុព្វលាភធានារ៉ាប់រង ដើម្បីទទួលបានការការពាររយៈពេល ២០ ឆ្នាំ។

### 2. តើផលិតផល SAFElife មានអត្ថប្រយោជន៍នៅពេលដល់កាលកំណត់នៃបណ្ណសន្យារ៉ាប់រងដែរឬទេ?

ផលិតផល SAFElife មិនមានផ្តល់អត្ថប្រយោជន៍ពេលដល់កាលកំណត់នៃបណ្ណសន្យារ៉ាប់រងនោះទេ ព្រោះលក្ខណៈពិសេសរបស់ផលិតផល SAFElife គឺផ្តោតសំខាន់លើការការពារដែលមានរយៈពេលវែងរហូតដល់ ២០ ឆ្នាំ ជាមួយនឹងការបង់បុព្វលាភធានារ៉ាប់រងក្នុងតម្លៃសមរម្យ។

### 3. តើបុព្វលាភធានារ៉ាប់រងដែលខ្ញុំត្រូវបង់មានការផ្លាស់ប្តូរដែររឺទេ?

រាល់បុព្វលាភធានារ៉ាប់រងដែលលោកអ្នកត្រូវបង់នឹងមិនមានការផ្លាស់ប្តូរឡើយក្នុងរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រងរហូតដល់កាលបរិច្ឆេទផុតកំណត់នៃបណ្ណសន្យារ៉ាប់រង។ ប៉ុន្តែបុព្វលាភធានារ៉ាប់រងរបស់លោកអ្នកអាចមានការផ្លាស់ប្តូរ ប្រសិនបើលោកអ្នកមានការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ នៅពេលបណ្ណសន្យារ៉ាប់រងរបស់លោកអ្នកអស់សុពលភាពជាបណ្តោះអាសន្ន ហើយលក្ខខណ្ឌសុខភាព ឬក៏លក្ខខណ្ឌណាមួយរបស់លោកអ្នកមានការផ្លាស់ប្តូរខុសពីលក្ខខណ្ឌនៅពេលលោកអ្នកជាវបណ្ណសន្យារ៉ាប់រងដំបូង។

### 4. តើខ្ញុំអាចធ្វើការផ្លាស់ប្តូរការបង់បុព្វលាភធានារ៉ាប់រង (ចំនួនដងនៃការបង់បុព្វលាភធានារ៉ាប់រងក្នុងមួយឆ្នាំ ឬវិធីទូទាត់បុព្វលាភធានារ៉ាប់រង) បានដែរឬទេ?

លោកអ្នកអាចធ្វើការផ្លាស់ប្តូរការបង់បុព្វលាភធានារ៉ាប់រង (ចំនួនដងនៃការបង់បុព្វលាភធានារ៉ាប់រងក្នុងមួយឆ្នាំ ឬវិធីទូទាត់បុព្វលាភធានារ៉ាប់រង) របស់លោកអ្នកបាន ហើយការផ្លាស់ប្តូរនេះនឹងមានសុពលភាពនៅថ្ងៃខួបបន្ទាប់នៃបណ្ណ សន្យារ៉ាប់រងរបស់លោកអ្នកតែប៉ុណ្ណោះ។ លោកអ្នកត្រូវធ្វើការបំពេញទម្រង់បែបបទក្នុងការស្នើសុំនេះក្នុងរយៈពេល៣០ថ្ងៃមុនដល់ខួបនៃបណ្ណសន្យារ៉ាប់រងរបស់លោកអ្នក។លោកអ្នកអាចធ្វើតាមជំហានខាងក្រោមក្នុងការស្នើសុំផ្លាស់ប្តូរវិធីទូទាត់បុព្វលាភធានារ៉ាប់រងរបស់លោកអ្នក ៖

- លោកអ្នកត្រូវបំពេញទម្រង់បែបបទស្នើសុំការផ្លាស់ប្តូរវិធីទូទាត់បុព្វលាភធានារ៉ាប់រង ដោយបញ្ជូនសំណើនោះមកកាន់ទីប្រឹក្សាហិរញ្ញវត្ថុ ឬទីប្រឹក្សាធានារ៉ាប់រងអាយុជីវិត ឬផ្ញើមកកាន់មជ្ឈមណ្ឌលផ្តល់សេវាអតិថិជនព្រូដិនសលកម្ពុជា ឬតាមរយៈសារអេឡិចត្រូនិច info@prudential.com.kh។ ចំនួនបុព្វលាភធានារ៉ាប់រងរបស់លោកអ្នកនឹងមានការផ្លាស់ប្តូរ បន្ទាប់ពីលោកអ្នកបានផ្លាស់ប្តូរការបង់បុព្វលាភធានារ៉ាប់រង (ចំនួនដងនៃការបង់បុព្វលាភធានារ៉ាប់រងក្នុងមួយឆ្នាំ ឬវិធីទូទាត់បុព្វលាភធានារ៉ាប់រង) របស់លោកអ្នក។
- លោកអ្នកត្រូវលុបចោលនូវបញ្ជាអចិន្ត្រៃយ៍ចាស់របស់លោកអ្នក (ប្រសិនបើមាន) ឬដាក់សំណើសុំនូវការប្រើប្រាស់បញ្ជាអចិន្ត្រៃយ៍

ថេរថ្មី ប្រសិនបើលោកអ្នកធ្វើការបង់បុព្វលាភធានារ៉ាប់រងតាមរយៈគណនីធនាគារ។

## 5. តើមានអ្វីកើតឡើងនៅពេលដែលខ្ញុំខកខានបង់បុព្វលាភធានារ៉ាប់រងនៅពេលកាលបរិច្ឆេទដល់កំណត់បង់បុព្វលាភធានារ៉ាប់រង?

ក្នុងករណីដែលលោកអ្នកខកខានមិនបានបង់បុព្វលាភធានារ៉ាប់រងនៅកាលបរិច្ឆេទដល់កាលកំណត់បង់បុព្វលាភធានារ៉ាប់រងដោយប្រការណាមួយ ព្រូដិនសលកម្ពុជានឹងផ្តល់រយៈពេល ៣០ថ្ងៃ ដល់លោកអ្នកក្នុងការបង់បុព្វលាភធានារ៉ាប់រងរបស់លោកអ្នក ដោយលោកអ្នកនៅតែទទួលបានការការពារពេញលេញ។

ប្រសិនបើលោកអ្នកនៅតែខកខានមិនបានបង់បុព្វលាភធានារ៉ាប់រងរបស់លោកអ្នកលើសពី ៣០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទដល់កំណត់បង់បុព្វលាភធានារ៉ាប់រង នោះបណ្ណសន្យារបស់លោកអ្នកនឹងអស់សុពលភាពជាបណ្តោះអាសន្ន ហើយលោកអ្នកនឹងមិនមានទទួលបានការធានារ៉ាប់រងឡើយប្រសិនបើមានការទាមទារសំណងណាមួយកើតឡើង។

លោកអ្នកអាចដាក់ពាក្យស្នើសុំបន្តសុពលភាពបណ្ណសន្យារ៉ាប់រងរបស់លោកអ្នកឡើងវិញបានក្នុងអំឡុងពេល២៤ខែគិតចាប់ពីកាលបរិច្ឆេទដល់កំណត់បង់បុព្វលាភធានារ៉ាប់រងដែលមិនបានបង់ដំបូងបង្អស់ ប៉ុន្តែមិនឲ្យហួសពីកាលបរិច្ឆេទផុតកំណត់នៃបណ្ណសន្យារ៉ាប់រងរបស់លោកអ្នកឡើយ។

ចំពោះបណ្ណសន្យារ៉ាប់រងដែលអស់សុពលភាពជាបណ្តោះអាសន្ន លោកអ្នកអាចតម្រូវឲ្យមានការវាយតម្លៃទៅលើលក្ខខណ្ឌសុខភាព មុខរបរ ឬលក្ខខណ្ឌផ្សេងៗទៀតសារជាថ្មីប្រសិនបើលក្ខខណ្ឌទាំងនោះមានការផ្លាស់ប្តូរដោយយោងតាមខនិងលក្ខខណ្ឌរបស់បណ្ណសន្យារ៉ាប់រង។ ដូចនេះហើយ ក្រុមហ៊ុនលើកទឹកចិត្តឲ្យអតិថិជនជួបជាមួយនឹងទីប្រឹក្សាហិរញ្ញវត្ថុ ឬទីប្រឹក្សាធានារ៉ាប់រងអាយុជីវិតពាក់ព័ន្ធនឹងការបង់បុព្វលាភធានារ៉ាប់រង ព្រោះការខកខាននេះអាចធ្វើឲ្យអតិថិជនស្ថិតក្នុងហានិភ័យផ្នែកហិរញ្ញវត្ថុ ។

## 6. ប្រសិនបើខ្ញុំជួបប្រទះការលំបាកនៅថ្ងៃមុខដែលតម្រូវឲ្យខ្ញុំបោះបង់បណ្ណសន្យារ៉ាប់រង តើខ្ញុំនឹងទទួលបានអត្ថប្រយោជន៍អ្វីត្រឡប់មកវិញ?

ប្រសិនបើលោកអ្នកជួបប្រទះនូវបញ្ហាលំបាកណាមួយដែលនាំឲ្យលោកអ្នកបោះបង់បណ្ណសន្យារ៉ាប់រងរបស់លោកអ្នក នោះលោកអ្នកនឹងមិនទទួលបាននូវទឹកប្រាក់ត្រូវបានធានាសម្រាប់ការបោះបង់បណ្ណសន្យារ៉ាប់រងនោះទេដោយយោងទៅតាមខនិងលក្ខខណ្ឌ និងលក្ខណៈពិសេសរបស់ផលិតផល SAFElife ដែលបានផ្តោតសំខាន់លើការការពារដែលមានរយៈពេលវែងជាមួយនឹងតម្លៃបុព្វលាភធានារ៉ាប់រងសមរម្យ។




សម្រាប់ព័ត៌មានលម្អិតសូមទាក់ទងមកកាន់

023 964 222 FREE* 1800-21 22 23

*សម្រាប់ក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះ

លោកអ្នកអាចមកកាន់មជ្ឈមណ្ឌលផ្តល់សេវាអតិថិជនរបស់
ក្រុមហ៊ុនព្រូដិនសល (ខេមបូឌា) ឡាយហ្វ៍ អឺស្សួរិនស៍ ម.ក
អគារវីត្រាស់ថាវើរ៍ ជាន់ផ្ទាល់ដី ផ្ទះលេខ 24 ផ្លូវលេខ 169 (មហាវិថីឆេកូស្លូវ៉ាគី)
សង្កាត់វាលវង់ ខណ្ឌ 7 មករា រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ 417
អ៊ីម៉ែល: info@prudential.com.kh
គេហទំព័រ: www.prudential.com.kh
ហ្វេសប៊ុក: Prudential Cambodia